# (០៣)

## អនុក្រឹត្យស្ដីពី

## ការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង
## នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
## និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះ
## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ: ១០៥ អនក្រ.បក

ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥

## ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខ: ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបន្ថែមមុខងារ ភារកិច្ច ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

### មាត្រា ១.-

ត្រូវបានបន្ថែមមុខងារភារកិច្ច ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ នៃផលិតផលកសិកម្មទាំងអស់ចាប់ពីការផ្តើមផលិតដំដុះរហូតដល់តំណាក់កាលចុងក្រោយ នៃការកែច្នៃបឋម ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ និងត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

អង្គការលេខថ្មី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២._

អង្គភាពដែលមានភារកិច្ច អនុវត្តមុខងារភារកិច្ចបន្ថែមដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ និងសកម្មភាពពាក់ព័ន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៣._

នាយកដ្ឋានផែនការ និង ស្ថិតិ មានភារកិច្ច ÷

- វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលខ្លី មធ្យម និងវែង និងតាមដានការអនុវត្ត
- ដឹកនាំអនុវត្តការអង្កេតទូទៅ ការអង្កេតតាមផ្នែករបស់វិស័យកសិកម្ម ប្រមូលព័ត៌មាន ស្ថិតិកសិកម្ម វិភាគវាយតម្លៃ និងចងក្រងឯកសារ
- រៀបចំ-កសាងកម្មវិធីវិនិយោគសាធារណៈ និងរៀបចំតម្រង់ទិសកម្មវិធីវិនិយោគឯកជន ក្នុងវិស័យកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍គោលដៅអាហារូបត្ថម្ភ
- ស្រាវជ្រាវ និង ផ្សព្វផ្សាយអំពីថ្លៃកសិផល និងតម្រូវការផលិតផលកសិកម្មគ្រប់ប្រភេទ នៅទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ សម្រាប់កសិករងាយស្រួលជ្រើសរើសធ្វើផលិតកម្មកសិកម្ម
- ទំនាក់ទំនងសហការជាមួយស្ថាប័ននានាក្នុងក្របខ័ណ្ឌការងារវិនិយោគនិងគម្រោងផែនការ ដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មាត្រា ៤._

នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ÷

- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម តាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចា និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ
- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមជំនួយទានរបស់ជំនួយទ្វេភាគី ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយក្រសួង ស្ថាប័ននានា
- តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យកសិកម្មដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា
- ចងក្រង និងគ្រប់គ្រងទិន្នន័យ ឯកសារដែលទាក់ទងនឹងកិច្ចការអន្តរជាតិ លើវិស័យកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មាត្រា ៥._

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម មានភារកិច្ច ÷

- ប្រមូលចងក្រង និងរក្សាទុកនូវ លិខិតបទដ្ឋាន ឯកសារ ព្រឹត្តិប័ត្រ និងអត្ថបទនានាដែលពាក់ព័ន្ធដល់ការ

គ្រប់គ្រងស្រាវជ្រាវគោលនយោបាយកម្មវិធី ផែនការ ស្ថិតិ និងទិន្នន័យបម្រើឱ្យកិច្ចអភិវឌ្ឍវិស័យកសិកម្ម និង សេដ្ឋកិច្ច ។

-ផ្តល់ព័ត៌មាន និងទិន្នន័យកសិកម្មដល់អតិថិជន ដែលមានជាអាទិ៍ អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ភ្នាក់ងារឯកជន ស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ តាមរយៈការអាន និងសិក្សានៅនឹងកន្លែង និងតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង

- ធ្វើការចងក្រង ផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាព នូវសមិទ្ធផលកសិកម្ម លិខិតបទដ្ឋាន គោលនយោបាយ បេសកកម្ម រចនាសម្ព័ន្ធគ្រប់គ្រង និងសមាសភាពថ្នាក់ដឹកនាំនៃក្រសួង តាមរយៈគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

-ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ដឹកនាំដោយប្រធានមួយរូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា ៦.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។

មាត្រា ៧.-

ក្រៅពីអនុក្រឹត្យថ្មីនេះ និងក្រៅពីមាត្រា ១០ ខ្លឹមសារ នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅ រក្សាជាធរមានដដែល ។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ [illegible] ឆ្នាំ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចក្នុងមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ .៩៩.. អនក្រ.បក ចុះថ្ងៃទី... ឆ្នាំ ២០០៥

រចនាសម្ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

